# សេចក្តីសំរេច
# ស្តីពី គោលការណ៍សំរាប់ការអប់រំ ការបណ្តុះបណ្តាល និង
# ការកសាងសមត្ថភាពដើម្បីគាំទ្រការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ

ដោយ : គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

កាលបរិច្ឆេទរៀបចំឯកសារ : ២៩-៤-២០០២

ស្ថាប័នរៀបចំឯកសារ : គណកម្មាធិការជាតិគាំទ្រឃុំសង្កាត់

សំរេច

ជំពូកទី ១ : បទប្បញ្ញត្តិទូទៅ

ជំពូកទី ២ : ទិសដៅនៃការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព

ជំពូកទី ៣ : បេសកកម្មរបស់អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

ជំពូកទី ៤ : ដំនើរការនៃការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព

ជំពូកទី ៥ : វិធីសាស្ត្រ

ជំពូកទី ៦ : ការសំរបសំរួល ការត្រួតពិនិត្យតាមដាន និងការវាយតំលៃ

គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

លេខ : ០៥៣ សរ,គ.ឃ.ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០២

## សេចក្តីសំរេច

## ស្តីពី គោលការណ៍ សំរាប់ការអប់រំ ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាព

## ដើម្បីគាំទ្រការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស,រកត,១១៩៨,៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២,នស,៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស,រកម,០១៩៦,០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស,រកម,០៣០១,០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស,រកត,៥០១,១៧៥ ចុះថ្ងៃ ទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០០២ ។

## សំរេច

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

ប្រការ ១ : ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព គឺជាមធ្យោបាយដំបូងក្នុងការសំរេចទិសដៅ ដែលបានកំនត់សំរាប់អនុវត្តនូវការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមគោលការណ៍វិមជ្ឈការ ។

## ជំពូកទី ២

## ទិសដៅនៃការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព

ប្រការ ២ : ការអប់រំការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ព្រមទាំងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ ព័ន្ធ។ ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវធ្វើអោយមុខសញ្ញានានាមានលទ្ធភាព ទទួលបាន ៖

- ឥរិយាបទត្រឹមត្រូវ ដែលចាំបាច់ ដើម្បីអនុវត្តនូវតួនាទី និងមុខងាររបស់ខ្លួនដែលបានកំនត់
- ជំនាញ ដែលពាក់ព័ន្ធ
- ចំនេះដឹងសមស្រប ។

ប្រការ ៣ : ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវរៀបចំ និងអនុវត្តទៅតាមរបៀប ដែលធ្វើអោយអ្នកដែលពាក់ព័ន្ធមានលក្ខណសម្បត្តិដើម្បី ៖

-លើកកំពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ

-ពង្រឹងប្រសិទ្ធិភាពសេវារបស់រាជរដ្ឋាភិបាល និងសេវាសាធារណ:

-ធ្វើអោយប្រជាជនសាមញ្ញ មានឱកាសកាន់តែច្រើន ក្នុងការសំរេចចិត្តលើអនាគតរបស់ខ្លួន

-លើកកំពស់ការចូលរួមដោយស្មើភាពគ្នារវាងបុរស និងស្ត្រីនៅក្នុងដំនើរការ និងផលប្រយោជន៍នៃវិមជ្ឈការ

-ធានាអោយមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋានផង ។

ប្រការ ៤ : ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព នឹងត្រូវផ្តល់ចំពោះមុខសញ្ញាដូចខាងក្រោម ៖

-សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-ស្មៀនឃុំ សង្កាត់ និងបុគ្គលិកផ្សេងទៀតរបស់ឃុំ សង្កាត់

-មេភូមិ

-មន្ត្រីមួយចំនួនរបស់រដ្ឋបាលថ្នាក់កណ្តាល មន្ទីរនៅថ្នាក់ខេត្ត ក្រុង និងការិយាល័យជំនាញនៅ ថ្នាក់ស្រុក ខណ្ឌ

-សាធារណជន ជាពិសេសប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ ។

## ជំពូកទី ៣

## បេសកកម្មរបស់អនុគណកម្មការអប់រំ បណ្តុះបណ្តាល និង

## កសាងសមត្ថភាព និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

ប្រការ ៥ : អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាពនៃគណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ "គ.ឃ.ស." មានភារកិច្ចជួយ គ.ឃ.ស. ក្នុងការសំរបសំរួលគ្រប់ទិដ្ឋភាពទាំងអស់ ដែលទាក់ទងទៅនឹងការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីធានាអោយមានការធ្វើអន្តរាគមន៍សមស្រប ក្នុងការកសាងសមត្ថភាពសំរាប់អ្នកដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព ត្រូវជំរុញការអនុវត្តន៍សកម្មភាពអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាពអោយទាន់ពេលវេលា និងនៅតាមវិជ្ជាជីវៈ និងជំនាញ ។

ប្រការ ៦ : នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដែលជាលេខាធិការដ្ឋាននៃគណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងជាសេនាធិការរបស់ក្រសួងមហាផ្ទៃ ត្រូវទទួលខុសត្រូវលើការងារទាំងអស់ដែលទាក់ទងទៅនឹងវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងពិនិត្យតាមដាន និងវាយតំលៃសមត្ថភាពរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ។ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ជាអ្នកធានារៀបចំ និងអនុវត្តនូវកម្មវិធីអប់រំ បណ្តុះបណ្តាល និងតំរង់ទិសអំពីវិមជ្ឈការ និងអភិបាលកិច្ចនៃឃុំ សង្កាត់ សំរាប់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់រាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងបុគ្គលិកផ្សេងៗទៀតរបស់ឃុំ សង្កាត់ ព្រមទាំងសាធារណជន ។

ប្រការ ៧ : អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋានមាន ភារកិច្ចទទួលខុសត្រូវក្នុងការធានាអោយបានថា រាល់សកម្មភាពកសាងសមត្ថភាពត្រូវរៀបចំ និងអនុវត្ត អោយបានសមស្រប ដើម្បីធ្វើអោយអ្នកដែលមានការពាក់ព័ន្ធមានលទ្ធភាពបំពេញនូវតួនាទី និងការទទួល ខុសត្រូវថ្មីរបស់ខ្លួនយ៉ាងមានប្រសិទ្ធិភាព ដោយអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ។

ប្រការ ៨ : អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវទទួលខុសត្រូវចំពោះ ៖

- ការគៀងគរធនធាន និងការរួមវិភាគទានពីប្រភពអ្នកផ្តល់ជំនួយទាំងអស់

- ការកំនត់ និងការធានាស្តង់ដារជាអប្បបរមាមួយចំនួនសំរាប់ខ្លឹមសារ និងវិធីសាស្រ្ត នៃ វិធានការកសាងសមត្ថភាព

- ការបង្កើតឯកសារគាំទ្រទៅតាមស្តង់ដារ

- ការសំរបសំរួល ការរួមវិភាគទានផ្សេងៗ

- ការពិនិត្យតាមដាន និងវាយតំលៃលើសកម្មភាពទាំងអស់។ ការកំនត់នីតិវិធី និងយន្តការសំរាប់សំរបសំរួល ផ្សព្វផ្សាយព័ត៌មាន និងផ្លាស់ប្តូរបទពិសោធន៍ គឺជាភារកិច្ចដែលមានអាទិភាព ។

## ជំពូកទី ៤

## ដំនើរការនៃការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព

ប្រការ ៩ : ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព គឺជាដំនើរការយូរអង្វែង ដែលទាមទារ អោយមានការប្រឹងប្រែងជាប្រចាំក្នុងរយពេលច្រើនឆ្នាំ ។ ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវមានការធ្វើអន្តរាគមន៍នៅពេលចាំបាច់ ដែលបានរៀបចំឡើងស្របទៅតាមកំរិតសមត្ថភាព ។ ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវមានការធ្វើអន្តរាគមន៍នៅពេលចាំបាច់ ដែលបានរៀបចំឡើងស្របទៅតាមកំរិតសមត្ថភាព។ ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវឆ្លើយតបទៅនឹងតំរូវការចំពោះការ កសាងសមត្ថភាពជាបន្ទាន់ និងតំរូវការក្នុងរយពេលវែង ។ ការធ្វើអន្តរាគមន៍ ដែលមានអាទិភាពមួយចំនួន ត្រូវរៀបចំ និងអនុវត្តដើម្បីផ្តល់ជូនអ្នកដែលពាក់ព័ន្ធនូវចំនេះដឹងជាមូលដ្ឋានជំនាញ និងអិរិយាបថ សំរាប់អនុវត្តនូវតួនាទី និងការទទួលខុសត្រូវបន្ទាប់ពីការបោះឆ្នោតរួច។ សកម្មភាពសំរាប់ឆ្នាំនីមួយៗ ត្រូវ ស្របទៅតាមតំរូវការជាអាទិភាពនៃមុខសញ្ញានីមួយៗ ។ ការកំនត់ជំនាក់កាលសំរាប់សកម្មភាពជាក់ ស្តែង ត្រូវទាក់ទងទៅនឹងការទទួលខុសត្រូវជាក់លាក់របស់មុខសញ្ញានីមួយ។

ប្រការ ១០ : ការកសាងសមត្ថភាព គឺជាការធ្វើអន្តរាគមន៍ខុសៗគ្នា ដែលបំពេញបន្ថែមអោយគ្នាទៅវិញទៅមក ។ ការធ្វើអន្តរាគមន៍នេះរួមមាន ការអប់រំ ការបណ្តុះបណ្តាល ការបោះពុម្ពសៀវភៅឯកសារ សៀវភៅ ពតិមាន ព្រឹត្តិប័ត្រពតិមាន និងការអប់រំតាមបណ្តាញពតិមាន ដូចជា វិទ្យុ ទូរទស្សន៍ និងកាសែត ។

ប្រការ ១១ : ការអប់រំ និងការបណ្តុះបណ្តាល គឺជាការធ្វើអន្តរាគមន៍យ៉ាងសំខាន់នៅក្នុងការកសាងសមត្ថភាព ដើម្បីធានាដល់គុណភាព និងស្តង់ដារួមដោយ ៖

-បណ្តុះបណ្តាលគ្រូឧទ្ទេស ដោយផ្អែកទៅលើឯកសារជាមូលដ្ឋានសំរាប់បង្រៀន និងសំរាប់ រៀន

-ផ្តល់ឯកសារសំរាប់បង្រៀន និងសំរាប់រៀនសូត្រ ដូចជា គំរោងមេរៀន និងឯកសារផ្សេង ទៀតដល់សិក្ខាកាម

-មានការចូលរួមរបស់គ្រូឧទ្ទេស ទាំងបុរស និងស្រ្តី

-ផ្តល់ឱកាសសំរាប់អនុវត្តន៍នៅក្នុងអំឡុងពេលបណ្តុះបណ្តាល

-ផ្តល់ឱកាសសំរាប់វាយតំលៃ និងចែករំលែកបទពិសោធន៍

-មានការសាកល្បងនៅនឹងកន្លែង និងការវាយតំលៃឧបករណ៍សំរាប់បង្រៀន និងសំរាប់ រៀនមុនពេលផ្សព្វផ្សាយនៅទូទាំងប្រទេស

-ផ្ដល់ឱកាសសំរាប់អោយអ្នកដែលពាក់ព័ន្ធ ទទួលបានការបណ្ដុះបណ្ដាលជាមួយគ្នា ដើម្បី លើកកំពស់កិច្ចសហប្រតិបត្តិការ និងការបង្កើតទំនាក់ទំនងការងារជាមួយគ្នា

-មានការជ្រើសរើសកន្លែងបណ្ដុះបណ្ដាល អោយនៅជិតកន្លែងធ្វើការរបស់សិក្ខាកាម ។

ប្រការ ១២ : ការអប់រំ ការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាព ត្រូវលើកកំពស់នូវគោលការណ៍ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញថាស្ត្រី និងបុរស មានសិទ្ធិ និងការទទួលខុសត្រូវស្មើគ្នា ។ ការផ្ដល់ចំនេះដឹង និងការកសាងសមត្ថភាពជំនាញ ត្រូវយកចិត្តទុកដាក់អំពីបញ្ហាសិទ្ធិសេរីភាព ស្មើភាពគ្នារវាងបុរស និងស្ត្រី ដែលជាផ្នែកមួយដ៏សំខាន់នៃការធ្វើអន្តរាគមន៍ក្នុងការកសាងសមត្ថភាព ។

## ជំពូកទី ៥

## វិធីសាស្ត្រ

ប្រការ ១៣ : វិធីសាស្ត្រទូទៅ ដែលអនុវត្តចំពោះការអប់រំ ការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាពត្រូវ ៖

-លើកទឹកចិត្តសិក្ខាកាម និងធ្វើអោយសិក្ខាកាមព្យាយាមរៀនសូត្រ

-សំរបទៅតាមកំរិតយល់ដឹង និងបទពិសោធន៍របស់សិក្ខាកាម

-ធានាផ្ដល់ឯកសារបង្រៀន និងរៀនសូត្រអោយបានសមស្រប

-ផ្ដល់ឱកាសសំរាប់វាយតំលៃ និងចែករំលែកបទពិសោធន៍ ។

ប្រការ ១៤ : អនុគណកម្មការអប់រំ បណ្ដុះបណ្ដាល និងកសាងសមត្ថភាព ត្រូវត្រួតពិនិត្យគ្រប់ឯកសារ សៀវភៅនានាសំរាប់បំរើអោយការអប់រំ ការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាព ដើម្បីធានាអោយបានថា រាល់ឯកសារ និងសៀវភៅទាំងនោះមានខ្លឹមសារត្រឹមត្រូវទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។ អនុគណកម្មការអប់រំ បណ្ដុះបណ្ដាល និងកសាងសមត្ថភាព ត្រូវជួយគណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្នុងការរៀបចំ និងបោះពុម្ពឯកសារ និងសៀវភៅនានាសំរាប់ផ្ដល់នូវភាពតំរង់ទិសជាមូលដ្ឋាន ដើម្បីអោយក្រុមប្រឹក្សាឃុំ សង្កាត់ អាចបំពេញការងារបាន ។ សៀវភៅឯកសារទាំងនោះ មានជាអាទិ៍ ៖

-ទស្សនទាន និងយុទ្ធសាស្ត្រកសាងសមត្ថភាព ដោយលើកឡើងលំអិតពីគោលការណ៍ ដែលបានរៀបរាប់ខាងលើ

-ការវាយតំលៃលើមុខសញ្ញាសំរាប់កសាងសមត្ថភាព និងការយល់ដឹង ព្រមទាំងតំរូវការ ចំពោះការបណ្ដុះបណ្ដាលជាបន្ទាន់

-វិធីសាស្ត្រនៃវិធានការកសាងសមត្ថភាព រួមមាន ការគ្រប់គ្រង ការសំរបសំរួលជាមួយអ្នក ផ្ដល់សេវាខុសៗគ្នា និង ការគាំទ្រផ្នែកហិរញ្ញវត្ថុការពិនិត្យតាមដាន និងការវាយតំលៃ

-ឯកសារមួយចំនួនសំរាប់កសាងការយល់ដឹងដូចជា ឯកសារសិក្ខាសាលា ឯកសារស្ដីពី ពត៌មានជាមូលដ្ឋាន និងបទឧទ្ទេសនាម

-ការកំនត់អាទិភាព ចំពោះវិធានការកសាងសមត្ថភាពសំរាប់មុខសញ្ញានីមួយៗ ។ សៀវភៅឯកសារសំរាប់អប់រំ បណ្ដុះបណ្ដាល និងកសាងសមត្ថភាពត្រូវរៀបចំជាភាសាសាមញ្ញ ខ្លីនិងច្បាស់លាស់ ស្របទៅតាមចំនេះដឹងរបស់មូលដ្ឋាន ។

ប្រការ ១៥ ៖ អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព ត្រូវសហការជាមួយគ្រប់ស្ថាប័ន ពាក់ព័ន្ធ ដើម្បីជម្រុញសកម្មភាពយុទ្ធនាការឃោសនាអប់រំសាធារណជន តាមរយៈវិទ្យុ និង ទូរទស្សន៍ អំពី ៖

-ទិសដៅនៃវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-តួនាទី និង ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-នីតិវិធីសំរាប់អោយប្រជាជននៅមូលដ្ឋានចូលរួមនៅក្នុងកិច្ចការមូលដ្ឋាន

-ការចូលរួមដោយស្មើភាពគ្នារវាងបុរស និងស្ត្រីនៅក្នុងកិច្ចការសហគមន៍

-សេវាសាធារណៈ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាឃុំ សង្កាត់

-សកម្មភាពមួយចំនួនរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ -ការសំភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ១៦ ៖ អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព ត្រូវជួយដល់គណកម្មាធិការគាំទ្រ ឃុំ សង្កាត់ ក្នុងការចងក្រង និងផ្សព្វផ្សាយពត៌មាន ព្រមទាំង ឯកសារអប់រំជាបន្ទាន់មួយចំនួនរួមមាន ៖

-សទ្ទានុក្រមស្តីពីពាក្យពេជន៍ទូទៅនៅក្នុងវិមជ្ឈការ និងវិសហមជ្ឈការ

-សៀវភៅពត៌មានស្តីពី "អ្វីខ្លះដែលលោក អ្នកចង់ដឹងពីវិមជ្ឈការ នៅកម្ពុជា" ដែលបក ស្រាយបញ្ហា និង ទស្សនសំខាន់ៗ នៅក្នុងការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

-សៀវភៅកំរងលិខិតបទដ្ឋាន ដែលពាក់ព័ន្ធសំរាប់គ្រប់គ្រងឃុំ សង្កាត់ តាមគោលនយោបាយវិមជ្ឈការ ដោយមានការបកស្រាយបន្ថែម

-សេចក្តីណែនាំសំរាប់ស្វ័យសិក្សាលើ "បទបញ្ជាសំរាប់ប្រជុំ"។

ប្រការ ១៧ ៖ ការបណ្តុះបណ្តាលអ្នកដែលពាក់ព័ន្ធនៅគ្រប់ថ្នាក់ទាំងអស់នៅក្នុងអភិបាលកិច្ច រួមមាន ៖

-សិក្ខាសាលានៅទូទាំងប្រទេស ដោយមានគោលដៅទៅលើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងតំនាងមួយចំនួននៅថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ

-ការរៀបចំ វគ្គបណ្តុះបណ្តាលខ្លីៗ សំរាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមតំរូវ ការបំពេញការងារចំពោះមុខ

-ការបណ្តុះបណ្តាលបំពេញបន្ថែមមួយចំនួនសំរាប់ស្មៀនឃុំ សង្កាត់ ស្តីពីលិខិតបទដ្ឋានក្រប ខ័ណ្ឌច្បាប់ ដែល បាន អនុម័តដោយគណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ បញ្ហាបច្ចេកទេស ទាក់ទងទៅនឹងរដ្ឋបាលឃុំ សង្កាត់ ការធ្វើផែនការ និងហិរញ្ញវត្ថុ

-ការបណ្តុះបណ្តាល និងការតំរង់ទិសមន្ត្រីខេត្ត ក្រុង និងស្រុក ខណ្ឌ លើបញ្ហាទាក់ទង ទៅនឹងវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តួនាទី និងមុខងាររបស់របស់ ខេត្ត ក្រុង និង ស្រុក ខណ្ឌ

-ការបណ្តុះបណ្តាល និងការតំរង់ទិសមន្ត្រីគ្រប់គ្រងមួយចំនួននៅក្នុងក្រសួងពាក់ព័ន្ធ ស្តីពី បញ្ហាទាក់ទងទៅនឹងវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-ការតំរង់ទិស និងការបណ្តុះបណ្តាលសំរាប់សមាជិករបស់គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុគណកម្មការ និង នាយកដ្ឋាន

រដ្ឋបាលមូលដ្ឋាន ស្តីពីវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ប្រការ ១៨ : អនុគណកម្មការអប់រំ បណ្តុះបណ្តាល និង កសាងសមត្ថភាព ត្រូវធ្វើផែនការសំរាប់ធ្វើអន្តរាគមន៍ លើការកសាងសមត្ថភាព ដូចជា ៖

-ទទួលយកទស្សនទាន និងយុទ្ធសាស្ត្រទូលំទូលាយសំរាប់ការធ្វើអន្តរាគមន៍កសាង សមត្ថភាពជាអាទិភាព

-បង្ហាញការប៉ាន់ស្មាន លើការចំណាយសំរាប់សកម្មភាពនានា ក្នុងការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព

-បង្ហាញផែនការការងារ និងផែនការសកម្មភាព សំរាប់ធ្វើការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព

-បង្ហាញរបាយការណ៍ប្រចាំត្រីមាស ស្តីពីការវិវត្តន៍របស់ការងារ ។

## ជំពូកទី ៦ ការសំរបសំរួល ការត្រួតពិនិត្យតាមដាន និងការវាយតំលៃ

មាត្រា ១៩ : ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ត្រូវធានាអោយក្រុមប្រឹក្សាឃុំ សង្កាត់ អាចដំនើរការបានជាបន្ទាន់ បន្ទាប់ពីបានចូលកាន់តំនែង ។

ប្រការ ២០ : ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ទាមទារអោយមានការប្រឹងប្រែងរួមគ្នាពីអង្គការ នានា ដូចជា ផ្នែកសាធារណ ផ្នែកឯកជន រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់ជំនួយជា លក្ខណទ្វេរភាគី និងពហុភាគី ។ ដើម្បីប្រើប្រាស់ធនធានអោយមានប្រសិទ្ធិភាព និងដើម្បីធានាគុណភាព ការប្រឹងប្រែងនេះ ចាំបាច់ ត្រូវមានការសំរបសំរួលជាមួយគ្នាយ៉ាងល្អ ។

ប្រការ ២១ : អនុគណកម្មការអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព ត្រូវពិនិត្យតាមដានអោយបានទៀងទាត់ ចំពោះសកម្មភាពអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព ។ បន្ទាប់ពីឃុំ សង្កាត់ បានដំនើរការក្នុងរយពេលមួយឆ្នាំ ត្រូវធ្វើការវាយតំលៃពីលទ្ធផលនៃការកសាងសមត្ថភាពនៅភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង និងនៅថ្នាក់ជាតិ។ លទ្ធផលនៃការដកពិសោធន៍ និងការវាយតំលៃនេះ ត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជូនដល់សាធារណជន និងត្រូវប្រើ ប្រាស់ដើម្បីកែសំរួល និងរៀបចំវិធានការកសាងសមត្ថភាពនៅពេលខាងមុខបន្តទៀត ។

ប្រការ ២២ : សេចក្តីសំរេចនេះ ចូលជាធរមានចាប់ពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជ.គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សហប្រធាន**

**ស ខេង យូ ហុកគ្រី**

**កន្លែងទទួល :**

**-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី**

**-ទីស្តីការគណរដ្ឋមន្ត្រី**

-សមាជិក គ.ឃ.ស

-ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប "

-អនុគណកម្មការ គ.ឃ.ស -លេខាធិការដ្ឋាន គ.ឃ.ស

-សាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ -មន្ទីរខេត្ត ក្រុងពាក់ព័ន្ធ "ដើម្បីមុខការ "

-ឯកសារ_កាលប្បវត្តិ